ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១៦)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៤ ៦៨៣នាក់ នៃរោងចក្រ សហគ្រាស ទាំង៤៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានប្រាក់ឧបត្ថម្ភលើកទី១ស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល ជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) របស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) នេះ នឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៤០ ៥០០រៀល (១០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ៣០ថ្ងៃ
- ២០២ ៥០០រៀល (៥០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៣១ថ្ងៃ ដល់ ៤៩ថ្ងៃ
- ២៤៣ ០០០រៀល (៦០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ៥០ថ្ងៃ ដល់ ២ខែ។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៤៤ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ សុក្រ ៤កើត ខែ ស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០២០

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០**

**បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍**
**ចំនួន ៤៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល លើកទី២ (លើកបញ្ចប់)**

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (លើកបញ្ចប់) | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 30 |
| 1 | ក្រុមហ៊ុនវូដុងអ៊ីនដាសស្ទ្រៀល | ភ្នំពេញ |
| 2 | ក្រុមហ៊ុនអេសអ៊ីភីអាយអេ (ខេមបូឌា) ហ្គាមេន ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុនសានស៊ូ ខ្លូស៊ីង (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុនម៉ាកាឡូត ហ្គាមិន (ខេមបូឌា) សាខាទី ១ | ភ្នំពេញ |
| 5 | ក្រុមហ៊ុនស៊ីម៉ូនី អេស៊ីស៊ី ខីលេកសិន | ភ្នំពេញ |
| 6 | ក្រុមហ៊ុនថុង ឆាវ អេនធើប្រាយ (ខេមបូឌា) អិលធីឌី | ភ្នំពេញ |
| 7 | ក្រុមហ៊ុនហ្វអេវើ ហ្គូដ ព្រីនធីង | ភ្នំពេញ |
| 8 | ក្រុមហ៊ុនវី.ស៊ី.អ៊ូ.អេហ្វ.អេហ្វ អឺភែរឺល ឯ.ក | ភ្នំពេញ |
| 9 | ក្រុមហ៊ុនត្រាកស៍ អឺភែរឺល (ខេមបូឌា) ខូអិលធីឌី | ភ្នំពេញ |
| 10 | រោងចក្រកាត់ដេរសម្លៀកបំពាក់ យូ.ឌី.អេស ហ្គាមេន | ភ្នំពេញ |
| 11 | ក្រុមហ៊ុន អ៊ិនធើ ហូបវែល ហ្គាមេន ខូអិលធីឌី | ភ្នំពេញ |
| 12 | ក្រុមហ៊ុនឌី&ជេ (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 13 | ក្រុមហ៊ុនហ៊ី លី តូ នីតធីង ខូ អិលធីឌី | ភ្នំពេញ |
| 14 | ក្រុមហ៊ុនប្រ៊ូដឡៃនខេមបូឌាហ្គាមែនអ៊ិនឌិសស្ទ្រី | ភ្នំពេញ |
| 15 | ក្រុមហ៊ុនភីភីអិន ភីសយ អឺថយខូអិលធីឌី | កណ្ដាល |
| 16 | ក្រុមហ៊ុនតេហ៊្វូអាំប្រេឡឺខូអិលធីឌី | កណ្ដាល |
| 17 | ក្រុមហ៊ុនដា រ៉ុង ព្រីនធីង & អ៊ីមប្រយឌើរី | កណ្ដាល |
| 18 | ក្រុមហ៊ុនលៀនហ្វា (ខេមបូឌា) ហ្គាមេន | កណ្ដាល |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស ទទួលប្រាក់ឧបត្ថម្ភលើកទី២ (បើកបញ្ចប់) | រាជធានី ខេត្ត |
| --- | --- | --- |
| 19 | ក្រុមហ៊ុនយី ដា មេនូហ្វេកឆឺរើ | កណ្ដាល |
| 20 | ក្រុមហ៊ុនចុង យ៉ូវ | កណ្ដាល |
| 21 | ក្រុមហ៊ុនញូខាំមើ ឡាក់ហ្គេដ អេនប៉ែក (ខេមបូឌា) មេនូហ្វេកធីរីង ឯ.ក | កំពង់ស្ពឺ |
| 22 | ក្រុមហ៊ុនអិមអេ ហ៉ែនប៉ែក (ខឹមបូឌា)ខូអែលធីឌី | កំពង់ស្ពឺ |
| 23 | ក្រុមហ៊ុនប្រេ្គត ភីស លីមីធីត | កំពង់ស្ពឺ |
| 24 | ក្រុមហ៊ុនខេមបូឌានស៊ីកនេតឈ័រ ថេកស្តាយ ឯ ក | ស្វាយរៀង |
| 25 | ក្រុមហ៊ុនយីងម៉េកឃើ(ខេមបូឌា)ហ្វូតវែរ | ស្វាយរៀង |
| 26 | ក្រុមហ៊ុនអ៊ីលីត (ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |
| 27 | ក្រុមហ៊ុនកៅវ៉េ ស្ព័ត អិលធីឌី | ស្វាយរៀង |
| 28 | ក្រុមហ៊ុនឡាយហ្វេងអៅដរ(ខេមបូឌា)ឯ.ក | តាកែវ |
| 29 | ក្រុមហ៊ុនណាតជាក (ខេមបូឌា) ឯ.ក | ព្រះសីហនុ |
| 30 | ក្រុមហ៊ុនធី.ខេ ហ្គាមេន ស៊ីសុផុន | បន្ទាយមានជ័យ |
| ខ. វិស័យទេសចរណ៍ | | 14 |
| 31 | ក្រុមហ៊ុនអេមខេត (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 32 | ក្រុមហ៊ុនសហគ្រាស-គ្រឹះស្ថាន ផ្លេនថេសិន ហូថេល | ភ្នំពេញ |
| 33 | ផ្ទះសំណាក់ប្លូមហ្គាឌិន | សៀមរាប |
| 34 | ក្រុមហ៊ុនណាវូទូ ឌ្រីម | សៀមរាប |
| 35 | ក្រុមហ៊ុនវេសថឺរេន ខូឡិចហ្សិន | សៀមរាប |
| 36 | ក្រុមហ៊ុនទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 37 | ក្រុមហ៊ុនអាហ្សូណា កាហ្វេធើរ៉ា | សៀមរាប |
| 38 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 39 | ក្រុមហ៊ុនអេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 40 | ក្រុមហ៊ុនចាយ៉ាហៅស៍រីវើរផាក សៀមរាប ឯ.ក | សៀមរាប |
| 41 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 42 | ក្រុមហ៊ុនភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 43 | ក្រុមហ៊ុនឋានសួគ៌សុខា | កំពត |
| 44 | ក្រុមហ៊ុនថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |